ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីទំហំ ៦៥ ហិកតា និង ៥៤ អា ចេញពីដីរដ្ឋដែលជាអតីតដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន និងធ្វើអនុបយោគដីទំហំ ៦០ ហិកតា និង ៥៨ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ៣២ គ្រួសារ និង រក្សាទុកទំហំ ៤ ហិកតា និង ៩៦ អា ជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ស្ថិតនៅភូមិដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីសរុបទំហំ ៦៥ ហិកតា និង ៥៤ អា ចេញពីដីរដ្ឋដែលជាអតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក យុន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ទំហំ ៦០ ហិកតា និង ៥៨ អា និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ៤ ហិកតា និង ៩៦ អា ស្ថិតនៅភូមិដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣២ គ្រួសារ នៅភូមិដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**មាត្រា៣ .-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៥៤ ក្បាលដី ក្នុងនោះ ក្បាលដីចំនួន ៤១ ក្បាលដី ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ៣២ គ្រួសារ ស្ថិតនៅភូមិដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

ដោយឡែកក្បាលដីចំនួន ១៣ ក្បាលដី ជាក្បាលដីគ្មានទិន្នន័យ ប្រគល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តគ្រប់គ្រងថែរក្សាការពារជាទ្រព្យសម្បត្តិរដ្ឋឱ្យមានប្រសិទ្ធភាព។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២១ ស្តីពីការកាត់ដីសរុបទំហំ ៦៥,៥៤ហិកតា ចេញពីផែនទីដីរដ្ឋ ដែលជាអតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុកឃុន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣២គ្រួសារ លើផ្ទៃដីទំហំ ៦០,៥៨ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំផ្ទះជាក់ស្តែង និងដីទំហំ ៤,៩៦ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិដំណាក់ត្រាច ឃុំដំបូករូង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ




| តារាងចំណុចនិយាមកា | | |
|---|---|---|
| ID | X | Y |
| 1 | 422766 | 1248490 |
| 2 | 422736 | 1248611 |
| 3 | 422733 | 1248700 |
| 4 | 422732 | 1249199 |
| 5 | 422744 | 1249235 |
| 6 | 422798 | 1249225 |
| 7 | 422801 | 1249266 |
| 8 | 422812 | 1249264 |
| 9 | 422860 | 1249256 |
| 10 | 422879 | 1249253 |
| 11 | 422916 | 1249246 |
| 12 | 422913 | 1249226 |
| 13 | 422908 | 1249183 |
| 14 | 422908 | 1249180 |
| 15 | 422984 | 1249174 |
| 16 | 422981 | 1249206 |
| 17 | 423098 | 1249213 |
| 18 | 423100 | 1249223 |
| 19 | 423115 | 1249220 |
| 20 | 423131 | 1249217 |
| 21 | 423155 | 1249213 |
| 22 | 423165 | 1249211 |
| 23 | 423169 | 1249210 |
| 24 | 423184 | 1249208 |
| 25 | 423181 | 1249201 |
| 26 | 423200 | 1249198 |
| 27 | 423213 | 1249184 |
| 28 | 423215 | 1249175 |
| 29 | 423233 | 1249174 |
| 30 | 423231 | 1249207 |
| 31 | 423227 | 1249234 |
| 32 | 423251 | 1249244 |
| 33 | 423276 | 1249255 |
| 34 | 423277 | 1249256 |
| 35 | 423291 | 1249262 |
| 36 | 423293 | 1249278 |
| 37 | 423363 | 1249290 |
| 38 | 423364 | 1249274 |
| 39 | 423386 | 1249278 |
| 40 | 423395 | 1249266 |
| 41 | 423431 | 1249112 |
| 42 | 423537 | 1249033 |
| 43 | 423465 | 1248941 |
| 44 | 423506 | 1248839 |
| 45 | 423484 | 1248773 |
| 46 | 423402 | 1248816 |
| 47 | 423362 | 1248704 |
| 48 | 423279 | 1248679 |
| 49 | 423159 | 1248541 |
| 50 | 423241 | 1248518 |
| 51 | 423227 | 1248346 |
| 52 | 423158 | 1248207 |
| 53 | 423094 | 1248201 |
| 54 | 423080 | 1248204 |
| 55 | 423002 | 1248194 |
| 56 | 422977 | 1248252 |
| 57 | 422963 | 1248282 |
| 58 | 422899 | 1248269 |
| 59 | 422885 | 1248267 |
| 60 | 422840 | 1248258 |
| 61 | 422807 | 1248256 |
| 62 | 422798 | 1248256 |
| 63 | 422776 | 1248131 |
| 64 | 422722 | 1248129 |
| 65 | 422709 | 1248127 |
| 66 | 422676 | 1248125 |
| 67 | 422648 | 1248124 |
| 68 | 422636 | 1248192 |
| 69 | 422633 | 1248221 |
| 70 | 422630 | 1248230 |
| 71 | 422597 | 1248272 |
| 72 | 422590 | 1248283 |
| 73 | 422580 | 1248293 |
| 74 | 422571 | 1248303 |
| 75 | 422536 | 1248352 |
| 76 | 422535 | 1248361 |
| 77 | 422623 | 1248420 |